**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ការិយាល័យ**
**អ្នកនាំពាក្យរាជរដ្ឋាភិបាលកម្ពុជា**
**លេខ: ០២៦/០១៩ នពរ**

# សេចក្តីថ្លែងការណ៍

**ការិយាល័យអ្នកនាំពាក្យរាជរដ្ឋាភិបាល** សូមសម្តែងនូវការគោរពគាំទ្របំផុត ចំពោះទស្សនៈប្រកបដោយឧត្តមគតិជាតិខ្ពស់របស់ **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** ដែលបានលើកឡើងកាលពីព្រឹកថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៩ ក្នុងឱកាសសម្តេចអញ្ជើញជាអធិបតីក្នុងវេទិកាស្តីពីភាពជាដៃគូ រវាងរាជរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិលថា *"អ្នកដែលប្រើពាក្យថា របបក្រុងភ្នំពេញ និងរបបលោក ហ៊ុន សែន គឺមិនគោរពឆន្ទៈរបស់ពលរដ្ឋខ្មែរ ដែលបានចេញទៅបោះឆ្នោតរហូតដល់៨៣ភាគរយ"*។

**ការិយាល័យអ្នកនាំពាក្យរាជរដ្ឋាភិបាល** នៅក្នុងបរិការណ៍នេះយល់ឃើញថា ការប្រើប្រាស់ពាក្យ *"របបក្រុងភ្នំពេញ និងរបបលោក ហ៊ុន សែន"* មានចរិតជាការញុះញង់ ធ្វើឱ្យនាំបំបែកបំបាក់សាមគ្គី និងឯកភាពជាតិរបស់កម្ពុជា ដែលបាននិងកំពុងរស់នៅក្នុងសង្គមមួយដែលមានសុខដុមនីយកម្ម និងកំពុងប្រកាន់យកការអនុវត្តតាមគោលការណ៍នីតិរដ្ឋយ៉ាងម៉ឺងម៉ាត់ ដើម្បីរួមចំណែកទៅដល់ការថែរក្សាសន្តិភាព ការការពារជាតិ ពង្រឹងឯករាជ្យភាព អធិបតេយ្យភាព បូរណភាពទឹកដី តាមរយៈការអនុវត្តគោលនយោបាយបង្រួបបង្រួមជាតិ ក្រោមដំបូលរដ្ឋធម្មនុញ្ញតែមួយ និងការដឹកនាំដោយ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**។

**ការិយាល័យអ្នកនាំពាក្យរាជរដ្ឋាភិបាល** សូមអំពាវនាវដល់រាល់ភាគីពាក់ព័ន្ធ និងបណ្តាញសារព័ត៌មានមួយចំនួន សូមសហការបញ្ឈប់ការប្រើប្រាស់ពាក្យមិនត្រឹមត្រូវនេះ។ បើពុំដូច្នេះទ **ការិយាល័យអ្នកនាំពាក្យរាជរដ្ឋាភិបាល** នឹងសើរើពិនិត្យចំពោះស្ថាប័នសារព័ត៌មានណា ដែលមិនឆ្លើយតបទៅនឹងការអំពាវនាវនេះ ដោយការប្រើប្រាស់ពាក្យដូចដែលបានលើកមកខាងលើ ដែលបានបង្កប់នូវអត្ថន័យ និងខ្លឹមសារប្រឆាំងនឹងសុឆន្ទៈប្រជាជនកម្ពុជា ដែលលោកចង់បានសន្តិភាព ស្ថិរភាពនយោបាយ ឯកភាព និងការអភិវឌ្ឍសង្គមក្រុមគ្រួសារ និងជាតិខ្មែរទាំងមូល ក្រោម រាជរដ្ឋាភិបាលជាប់ឆ្នោតអនុវត្តតាមគោលការណ៍លទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស ដែលឆ្លុះបញ្ចាំងសុឆន្ទៈប្រជាពលរដ្ឋខ្មែរទាំងមូល។

ថ្ងៃសុក្រ ១៣កើត ខែបុស្ស ឆ្នាំច សំរឹទ្ធិស័ក ព.ស២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៩